Ottawa County Health Department

# សន្លឹកព័ត៌មានសាធារណៈ

## ការពុលស៊ីហ្គេឡា [SHIGELLOSIS]

**តើការពុលស៊ីហ្គេឡា គឺជាអ្វី?**
ការពុលស៊ីហ្គេឡា គឺជាការឆ្លងមេរោគក្នុងពោះវៀន បង្កដោយបាក់តេរីមួយ ហៅថា "ស៊ីហ្គេឡា" ដែលអាចធ្វើឱ្យកើតរោគរាគអាចម៍ រមួលក្រពះ និងក្តៅខ្លួន យ៉ាងធ្ងន់ធ្ងរ ។ អ្នកខ្លះដែលឆ្លងមេរោគមិនមានរោគសញ្ញាសោះ ប៉ុន្តែនៅតែអាចចម្លងមេរោគឱ្យអ្នកផ្សេងបាន ។

**តើស៊ីហ្គេឡា ត្រូវបានឆ្លងតាមរបៀបអ្វីខ្លះ?**
ស៊ីហ្គេឡាអាចឆ្លងបាន តាមរបៀបទាំងឡាយខាងក្រោមនេះ:

ដោយបាក់តេរី ត្រូវបានផ្ទេរដោយដៃមិនស្អាតរបស់មនុស្សម្នាក់ ចូលមាត់របស់ម្នាក់ទៀត:

- ដោយការមិនលាងដៃត្រឹមត្រូវ ក្រោយពីដូរកន្ទបក្មេងមានមេរោគ
- ដោយការមិនលាងដៃត្រឹមត្រូវ ក្រោយពីអ្នកជម្ងឺបត់ជើងធំ

ដោយបរិភោគអាហារមិនស្អាត:

- សាច់ឆៅ ឬស្ងោរឆ្អិន
- បន្លែមិនស្អាត ដែលប្រឡាក់លាមកពីវាលមក

ដោយផឹក ឬហែល នូវទឹកដ៏មិនស្អាត
ដោយសត្វរុយយកមេរោគពីលាមក ទៅអាហារ

**តើអាចមានរោគសញ្ញាអ្វីខ្លះ?**
ធម្មតា រោគសញ្ញាកើតឡើង 1-3 ថ្ងៃក្រោយពីឆ្លងមេរោគ ។ រោគសញ្ញាទូទៅអាចមានរួមទាំង:

- រាគអាចម៍ (អាចមានឈាម ឬសំបោរ)
- ក្តៅខ្លួន
- ញាក់រងា
- រមួលក្រពះ
- ក្អួត/ចង់ក្អួត

*អ្នកជម្ងឺមួយចំនួនតិច ដែលឆ្លងស៊ីហ្គេឡា នឹងឈឺសន្លាក់ឆ្អឹង ក្រហាយភ្នែក និងឈឺពេលបត់ជើងតូច ដែលជម្ងឺនេះហៅថា រីទ័រ-ស៊ិនដ្រុម ។ វាអាចមានពីរាប់ខែ ដល់ទៅរាប់ឆ្នាំក៏មាន ហើយអាចនាំទៅកាន់ជម្ងឺហើមសន្លាក់ឆ្អឹងរ៉ាំរ៉ៃ ។*

**តើការពុលស៊ីហ្គេឡាត្រូវបានវិនិច្ឆ័យរោគយ៉ាងដូចម្តេច?**
ធម្មតា ស៊ីហ្គេឡាត្រូវបានវិនិច្ឆ័យរោគ ដោយពិនិត្យលាមក ។ ជារឿយៗ ការពិនិត្យលាមកបន្តបន្ទាប់ត្រូវបានធ្វើឡើង ដើម្បីបញ្ជាក់ពេលដែលអ្នកជម្ងឺអស់មេរោគពីខ្លួនហើយ ។

**តើការពុលស៊ីហ្គេឡាត្រូវបានព្យាបាលយ៉ាងដូចម្តេច?**
ធម្មតា ការពុលស៊ីហ្គេឡា ត្រូវបានព្យាបាលដោយថ្នាំអង់ទីប៊ីយ៉ូទិក ប៉ុន្តែអ្នកខ្លះដែលឈឺស្រាលជាង អាចជាបាន ដោយមិនបាច់មានថ្នាំ ។ ថ្នាំរាគ ដូចជា *Imodium* ឬ *Lomotil* ធ្វើឱ្យឈឺធ្ងន់ជាងទៅទៀត ហើយអ្នក**គួរតែចៀសវាងវា** ។
ដូចជាជម្ងឺក្អួត និងរាគផ្សេងៗ ទៀតដែរ ជាការសំខាន់ណាស់ ដែលអ្នកត្រូវរក្សាឱ្យមានជាតិទឹកក្នុងខ្លួនល្មម ដោយផឹកទឹកច្រើន ។

**តើការពុលស៊ីហ្គេឡាអាចបង្ការបានយ៉ាងដូចម្តេច?**

- អនុវត្តក្បួនអនាម័យល្អ
- លាងដៃដោយសាប៊ូជាញឹកញាប់ ជាពិសេសក្រោយពីបត់ជើង ដូរកន្ទបក្មេង ហើយមុនរៀបចំអាហារ និងភេសជ្ជៈ
- បោះចោលកន្ទបប្រឡាក់ដោយត្រឹមត្រូវ ហើយសម្លាប់មេរោគនៅកន្លែងដូរកន្ទប ដោយអូសាវ៉ែល ឡៃសល់ ឬ ក្រដាសជូតសម្លាប់បាក់តេរី ។
- ត្រួតមើលការលាងដៃរបស់កូនក្មេង
- ចៀសវាងកុំឱ្យលេបទឹកអាងហែល
- បើអ្នកមានជម្ងឺ កុំរៀបចំអាហារឱ្យអ្នកផ្សេងទេ

*អ្នកដែលមានរោគ មិនគួរធ្វើការរៀបចំម្ហូប ឬថែទាំកុមារ ទាល់តែការពិនិត្យលាមកបង្ហាញថាអស់ស៊ីហ្គេឡាពីរដង ។*

**សម្រាប់ព័ត៌មានបន្ថែមទៀតអំពីការពុលស៊ីហ្គេឡា ទាក់ទង:**
Ottawa County Health Department
www.miOttawa.org
Center for Disease Control and Prevention
www.bt.cdc.gov/
ទូរស័ព្ទ: (888) 246-2675

12251 James St., Suite 400
Holland, MI 49424
ទូរស័ព្ទ: (616) 396-5266
ទូរសារ: (616) 393-5643
វិបសាយ: www.miOttawa.org